**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ: ៧០១ អនក្រ.បក**

# អនុក្រឹត្យ
## ស្តីពី
## ឯកសណ្ឋាន ស្លាកសញ្ញា និងសញ្ញាសក្តិ មន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៩/១១ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៥១ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៩ និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០១២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៨ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៣/៨៩២ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៣ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៦ ស្តីពីការបង្កើតអគ្គនាយកដ្ឋានពន្ធនាគារ ក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ



www.pheakdeylaw.com

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.—**

អនុក្រឹត្យនេះមានគោលបំណងបង្កើត ឯកសណ្ឋាន ស្លាកសញ្ញា និងសញ្ញាសក្តិមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ។

**មាត្រា២.—**

អនុក្រឹត្យនេះមានគោលដៅ :

- កំណត់អំពីឯកសណ្ឋានមន្ត្រីពន្ធនាគារ
- កំណត់អំពីស្លាកសញ្ញាមន្ត្រីពន្ធនាគារ
- កំណត់អំពីសញ្ញាសក្តិមន្ត្រីពន្ធនាគារ។

**មាត្រា៣.—**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះមន្ត្រីពន្ធនាគារគ្រប់រូបដែលកំពុងបំពេញការកិច្ចនៅក្នុងរចនាសម្ព័ន្ធរបស់អគ្គនាយកដ្ឋានពន្ធនាគារ ក្រសួងមហាផ្ទៃ។

## ជំពូកទី២
## អំពីឯកសណ្ឋាន

**មាត្រា៤.—**

ឯកសណ្ឋានមន្ត្រីពន្ធនាគារសម្រាប់ប្រើប្រាស់ក្នុងពិធីបុណ្យផ្លូវការ ក្នុងពេលបំពេញការងារប្រចាំថ្ងៃ និងក្នុងពេលប្រតិបត្តិការ មាន ៦(ប្រាំមួយ) ប្រភេទ គឺ

- ឯកសណ្ឋានធំលេខ ១ "អាវវ៉ារី" សម្រាប់ប្រើប្រាស់ក្នុងព្រះរាជពិធីបុណ្យជាតិ :
  + អាវពណ៌ស ខោពណ៌បៃតង ប៉ានធ្នូតពីរពណ៌លឿងនៅចំហៀងពីលើចុះក្រោម សម្រាប់បុរស
  + អាវពណ៌ស សំពត់ពណ៌បៃតង ប៉ានធ្នូតពីរពណ៌លឿងព័ទ្ធជុំវិញជើងសំពត់ សម្រាប់នារី។
- ឯកសណ្ឋានធំលេខ ២ "អាវវ៉ារី" សម្រាប់ប្រើប្រាស់ក្នុងពិធីផ្លូវការនានា និងការទទួលភ្ញៀវជាតិ អន្តរជាតិ ។
  + អាវពណ៌ខ្លាញ់ក្ងោកចាស់ ខោពណ៌ខ្លាញ់ក្ងោកចាស់ សម្រាប់បុរស
  + អាវពណ៌ខ្លាញ់ក្ងោកចាស់ សំពត់ពណ៌ខ្លាញ់ក្ងោកចាស់សម្រាប់នារី។
- ឯកសណ្ឋានការងារលេខ ៣ " សាហារីយ៉េន" ពណ៌កាគីចាស់ : សម្រាប់ប្រើប្រាស់ក្នុងពិធីមិទ្ទិញ សិក្ខាសាលា និងសន្និបាតនានា។
  + អាវពណ៌កាគីចាស់ ខោពណ៌កាគីចាស់ សម្រាប់បុរស
  + អាវពណ៌កាគីចាស់ សំពត់ពណ៌កាគីចាស់ សម្រាប់នារី។
- ឯកសណ្ឋានការងារលេខ ៤ " ពណ៌កាគីចាស់ " សម្រាប់ប្រើប្រាស់ក្នុងពេលបំពេញការងារប្រចាំថ្ងៃ(អាវដៃវែង) ។
- ឯកសណ្ឋានការងារលេខ ៥ " ពណ៌កាគីចាស់ " សម្រាប់ប្រើក្នុងពេលបំពេញការងារប្រចាំថ្ងៃ(អាវដៃខ្លី) ។



www.pheakdeylaw.com

- ឯកសណ្ឋានការងារលេខ ៦ " ពណ៌បៃតងចាស់ " សម្រាប់ប្រើប្រាស់ក្នុងប្រតិបត្តិការសន្តិសុខ សុវត្ថិភាព។

**មាត្រា ៥.—**

ការកំណត់ទ្រង់ទ្រាយ និងរបៀបប្រើប្រាស់ឯកសណ្ឋានប្រភេទនីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ជំពូកទី៣
## អំពីរូបព្រះសង្ហារ និងស្លាកសញ្ញាសម្គាល់

**មាត្រា៦.—**

១- រូបព្រះសង្ហារ មាន ៣(បី) ប្រភេទ គឺ :

- រូបព្រះសង្ហារប្រភេទ ១ សម្រាប់ដាក់លើមុខមួកកាស្កេត
- រូបព្រះសង្ហារប្រភេទ ២ សម្រាប់ដាក់លើមុខមួកហ្សិកគី និងមួកសំបុក
- រូបព្រះសង្ហារប្រភេទ ៣ សម្រាប់ដាក់លើមុខមួកបេរ៉េ។

២- ស្លាកសញ្ញាសម្គាល់មន្ត្រីពន្ធនាគារ មាន ៥(ប្រាំ) ប្រភេទ គឺ :

- ស្លាកសញ្ញាសម្គាល់ប្រភេទ ១ សម្រាប់ពាក់បន្តោកភ្ជាប់នឹងឡេវហោប៉ៅអាវខាងស្តាំ
- ស្លាកសញ្ញាសម្គាល់ប្រភេទ២ សម្រាប់ដាក់លើដៃអាវខាងស្តាំ
- ស្លាកសញ្ញាសម្គាល់ប្រភេទ៣ សម្រាប់ដាក់លើដៃអាវខាងឆ្វេង
- ស្លាកសញ្ញាសម្គាល់ប្រភេទ៤ សម្រាប់ពាក់នៅលើចុងកអាវទាំងសងខាង នៃឯកសណ្ឋានលេខ ១ លេខ ២ លេខ៣ លេខ៤ លេខ៥ និងឯកសណ្ឋានប្រតិបត្តិការ
- ស្លាកសញ្ញាសម្គាល់ប្រភេទ៥ សម្រាប់ពាក់នៅលើគម្របហោប៉ៅអាវលើខាងស្តាំ (ស្លាកឈ្មោះ និងអត្តលេខ)។

៣- សញ្ញាសម្គាល់អតីតភាពការងារមន្ត្រីពន្ធនាគារ មាន ២(ពីរ)ប្រភេទ គឺ :

- សញ្ញាអតីតភាពការងារប្រភេទ ១ ពណ៌មាស ប្រើសម្រាប់ឋានន្តរសក្តិពីថ្នាក់វរអគ្គានុរក្សឡើង
- សញ្ញាអតីតភាពការងារប្រភេទ២ ពណ៌ប្រាក់ ប្រើសម្រាប់ឋានន្តរសក្តិពីថ្នាក់អគ្គានុរក្សចុះ។

**មាត្រា៧.—**

- រូបភាព របៀបរចនាម៉ូត ពណ៌ ទំហំខ្នាត និងរបៀបប្រើប្រាស់រូបព្រះសង្ហារ ស្លាកសញ្ញាសម្គាល់ប្រភេទនីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

- សម្ភារបំពាក់បន្ទាប់បន្សំផ្សេងៗទៀត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។



www.pheakdeylaw.com

## ជំពូកទី៤

## អំពីសញ្ញាសក្តិ

**មាត្រា៨.-**

សញ្ញាសក្តិរបស់មន្ត្រីពន្ធនាគារ មានដូចខាងក្រោម :

**ក. សញ្ញាសក្តិថ្នាក់ឧត្តមអគ្គានុរក្សពន្ធនាគារ និងវរអគ្គានុរក្សពន្ធនាគារ មាន ៣(បី) ប្រភេទ**

១- សញ្ញាសក្តិលើស្មា ប្រភេទ ១

សញ្ញាសក្តិលើស្មាប្រភេទ១ សម្រាប់ពាក់នៅលើឯកសណ្ឋានធំលេខ១ "អាវ៉ារីពណ៌ស"។

២- សញ្ញាសក្តិលើស្មា ប្រភេទ ២

សញ្ញាសក្តិលើស្មាប្រភេទ ២ សម្រាប់ពាក់នៅលើឯកសណ្ឋានធំលេខ ២ ឯកសណ្ឋានលេខ៣ ឯកសណ្ឋានការងារលេខ ៤ និងឯកសណ្ឋានការងារលេខ ៥។

៣- សញ្ញាសក្តិទ្រូង ប្រភេទ ៣

សញ្ញាសក្តិទ្រូងប្រភេទ៣ សម្រាប់ពាក់នៅលើទ្រូងនៃឯកសណ្ឋានការងារលេខ៦ "ឯកសណ្ឋានប្រតិបត្តិការ"។

ខ. សញ្ញាសក្តិថ្នាក់អគ្គានុរក្សពន្ធនាគារ និងអនុរក្សពន្ធនាគារ មាន ២(ពីរ)ប្រភេទ

១- សញ្ញាសក្តិលើស្មា ប្រភេទ ២

សញ្ញាសក្តិប្រភេទ២ សម្រាប់ពាក់នៅលើឯកសណ្ឋានការងារលេខ ៤ និងឯកសណ្ឋានការងារលេខ ៥ ។

២- សក្តិទ្រូង ប្រភេទ ៣

សក្តិទ្រូងប្រភេទ៣ សម្រាប់ពាក់នៅលើទ្រូងនៃឯកសណ្ឋានការងារលេខ ៦ " ឯកសណ្ឋានប្រតិបត្តិការ" ។

**មាត្រា៩.-**

របៀបរៀបចំរូបភាពសញ្ញាសក្តិ ពណ៌ ទំហំខ្នាត និងរបៀបប្រើប្រាស់ប្រភេទសក្តិនីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា១០.-**

ការផ្គត់ផ្គង់ឯកសណ្ឋាន ស្លាកសញ្ញានិងសញ្ញាសក្តិ ព្រមទាំងសម្ភារបំពាក់ផ្សេងៗទៀតជាបន្ទុករបស់រដ្ឋ។

ការកំណត់របបផ្គត់ផ្គង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។



www.pheakdeylaw.com

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា១១.-**

បទប្បញ្ញត្តិទាំងឡាយណាផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន ដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា សូមហត្ថលេខា។
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



www.pheakdeylaw.com